# ក្រមសីលធម៌សម្រាប់មជ្ឈត្តករ
# ដែលបានចុះបញ្ជី ឬប្រតិបត្តិក្រោមវិធានរបស់
# មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃ
# ព្រះរាជាណាចក្រកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៥**

# បុព្វកថា

ការប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយវិវាទផ្សេងៗនៅក្នុងពិភពជំនួញ បានកើនឡើងយ៉ាងខ្លាំង និងបង្កើតបានជាផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធយុត្តិធម៌ ដែលសង្គមរបស់យើងកំពុងត្រូវការសម្រាប់សម្រេចអំពីសិទ្ធិស្របច្បាប់ឲ្យបានត្រឹមត្រូវ។ ដូច្នេះបុគ្គលដែលធ្វើជាមជ្ឈត្តករត្រូវមានទំនួលខុសត្រូវច្បាស់លាស់ចំពោះសាធារណជនក៏ដូចជាគូភាគីវិវាទ។ ទំនួលខុសត្រូវទាំងនោះរួមបញ្ចូលទាំងកាតព្វកិច្ចក្រមសីលធម៌ដ៏មានសារៈសំខាន់ផងដែរ។

មជ្ឈត្តករក៏ដូចចៅក្រមដែរ មានអំណាចសម្រេចលើរឿងក្តីទាំងឡាយក្នុងដែនយុត្តាធិការរបស់ខ្លួន ប៉ុន្តែខុសពីចៅក្រមព្រោះមជ្ឈត្តករជាទូទៅមានមុខរបរដទៃផ្សេងទៀត នៅមុនពេល ក្នុងអំឡុងពេល និងនៅក្រោយពេលដែលពួកគេធ្វើជាមជ្ឈត្តករ។

ក្រមសីលធម៌នេះផ្តល់នូវគោលការណ៍ណែនាំអំពីសីលធម៌សម្រាប់មជ្ឈត្តករគ្រប់រូបដែលបានចុះបញ្ជីជាសមាជិករបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងមជ្ឈត្តករដែលបានតែងតាំងក្រោមវិធានមជ្ឈត្តការរបស់ ម.ជ.ម. ។

ក្រមសីលធម៌នេះបង្កើតឡើងដើម្បីធានាឲ្យមានអព្យាក្រឹតភាពសម្រាប់មជ្ឈត្តករទាំងអស់ រួមទាំងមជ្ឈត្តករដែលតែងតាំងដោយភាគីវិវាទ លើកលែងតែមានកិច្ចព្រមព្រៀងរបស់គូភាគីវិវាទ វិធានមជ្ឈត្តការដែល ព្រមព្រៀងដោយគូភាគីវិវាទ ឬច្បាប់ពាក់ព័ន្ធចែងផ្សេងពីនេះ។

ក្រមសីលធម៌នេះ មិនអាចយកទៅប្រើជាមូលដ្ឋាន ឬ កម្រិតនូវឆន្ទានុសិទ្ធិរបស់តុលាការក្នុងការសម្រេចលើការប្តឹងជំទាស់ ឬ ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យណាមួយឡើយ។

បញ្ជីដែលបានភ្ជាប់ជាមួយក្រមសីលធម៌នេះ ៖ **បញ្ជីពណ៌ក្រហម** និង**បញ្ជីពណ៌ទឹកក្រូច** ធ្វើឡើងដើម្បីរៀបរាប់ស្ថានភាពជាក់លាក់មិនដាច់ខាតមួយចំនួន ដែលធានាអំពីការលាតត្រដាង ក៏ដូចជាភាពគ្មានគុណវុឌ្ឍិរបស់មជ្ឈត្តករណាម្នាក់ ដូចបានកំណត់នៅក្នុងប្រការ៣ ដល់ប្រការ៨ ទាក់ទងនឹងទំនាស់ផលប្រយោជន៍ និង**បញ្ជីបៃតង** សម្រាប់កំណត់អំពីស្ថានភាពជាក់លាក់មួយចំនួនដែលមជ្ឈត្តករគ្មានករណីយកិច្ចលាតត្រដាងព័ត៌មានឡើយ។

យើងខ្ញុំទាំងអស់គ្នាជាសមាជិករបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានព្រមព្រៀងអនុម័ត និងអនុវត្តតាមក្រមសីលធម៌នេះដូចមានកំណត់ក្នុងប្រការនានានៃក្រមសីលធម៌នេះ៖

## ប្រការ១.- គោលការណ៍ទូទៅ

មជ្ឈត្តករគ្រប់រូបត្រូវចាប់ផ្តើមដំណើរការនីតិវិធីរបស់ខ្លួន ដើម្បីស្វែងរកដំណោះស្រាយជូនគូភាគីវិវាទ ដែលមានជម្លោះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។ នៅពេលទទួលយកការតែងតាំងជាមជ្ឈត្តករ មជ្ឈត្តករនោះមិនត្រូវមានភាពលំអៀង និងត្រូវមានភាព ឯករាជ្យ ចំពោះគូភាគីវិវាទ ហើយត្រូវរក្សាភាពមិនលំអៀង និងឯករាជ្យភាពនោះជារៀងរហូតនៅក្នុងអំឡុងពេល ដំណើរការនីតិវិធីរបស់ខ្លួន។ មជ្ឈត្តករមិនត្រូវទទួលរងសំពាធពីខាងក្រៅ មិនត្រូវខ្លាចការរិះគន់ ឬមិនត្រូវមាន ផលប្រយោជន៍ផ្ទាល់ខ្លួន ទោះបីក្នុងទម្រង់ណាក៏ដោយ ដែលអាចនាំឲ្យមានផលប៉ះពាល់ដល់ការសម្រេច សេចក្តីរបស់ខ្លួន និងត្រូវសម្រេចគ្រប់ការទាមទារទាំងអស់ដែលបានដាក់ជូនដើម្បីធ្វើសេចក្តីសម្រេច ក្រោយ ពីធ្វើការពិចារណាយ៉ាងហ្មត់ចត់ និងមិនលំអៀង។

## ប្រការ២.- ការទទួលយកការតែងតាំង

២.១ មជ្ឈត្តករមិនត្រូវស្នើសុំឲ្យភាគីវិវាទតែងតាំងខ្លួនក្នុងវេទិកាមជ្ឈត្តកម្ម។

២.២ មជ្ឈត្តករណាម្នាក់អាចទទួលយកការតែងតាំងបាន លុះត្រាតែមជ្ឈត្តករនោះទទួលស្គាល់ថា ខ្លួនមានសមត្ថភាពពេញលេញក្នុងការដោះស្រាយវិវាទ។

២.៣ មជ្ឈត្តករអាចទទួលយកការតែងតាំងបាន លុះត្រាតែមជ្ឈត្តករនោះអាចផ្តល់ពេលវេលា និង ការយកចិត្តទុកដាក់ពេញលេញចំពោះដំណើរការមជ្ឈត្តការតាមការរំពឹងទុករបស់គូភាគីវិវាទ ។

២.៤ មជ្ឈត្តករណាម្នាក់អាចទទួលយកការតែងតាំងបាន លុះត្រាតែមជ្ឈត្តករនោះទទួលស្គាល់យ៉ាង ពេញលេញថា គាត់អាចប្រតិបត្តិតួនាទីរបស់ខ្លួនតាមបញ្ញត្តិខាងក្រោម ដោយមិនលំអៀង និង ដោយឯករាជ្យភាព។

## ប្រការ៣.- ទំនាស់ផលប្រយោជន៍ ភាពមិនលំអៀង និងឯករាជ្យភាព

លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃអំពីបញ្ហាទាក់ទងនឹងទំនាស់ផលប្រយោជន៍ គឺភាពមិនលំអៀង និងឯករាជ្យភាព។ ភាពលំអៀងកើតឡើងនៅពេលដែលមជ្ឈត្តករគាំទ្រភាគីម្ខាង ឬ នៅពេលដែលមជ្ឈត្តករ នោះមានភាពលំអៀងទាក់ទងនឹងកម្មវត្ថុនៃវិវាទ។

ភាពមិនឯករាជ្យកើតឡើងពីទំនាក់ទំនងរវាងមជ្ឈត្តករជាមួយភាគីណាមួយ ឬ ជាមួយបុគ្គលណា មួយដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយភាគីវិវាទ។

## ប្រការ៤.- ទំនាស់ផលប្រយោជន៍ ករណីយកិច្ចដកខ្លួន ឬ ការបោះបង់ចោលការងារ

៤.១ មជ្ឈត្តករត្រូវបដិសេធមិនទទួលយកការតែងតាំង ឬ ប្រសិនបើដំណើរការមជ្ឈត្តការបានចាប់ផ្តើម ហើយ មជ្ឈត្តករត្រូវដកខ្លួនពីការងារ ប្រសិនបើ ៖

- មជ្ឈត្តករនោះមានមន្ទិលសង្ស័យអំពីសមត្ថភាពរបស់ខ្លួនទាក់ទងនឹងភាពមិនលំអៀង ឬ ឯករាជ្យភាព ឬ/និង
- កើតមាននូវស្ថានភាពណាមួយដែលបានកំណត់នៅក្នុង **បញ្ជីក្រហម** ។

៤.២ ផ្អែកតាមគោលការណ៍ទូទៅនៃទស្សនៈសមហេតុផល ប្រសិនបើមានហេតុ ឬ ស្ថានភាពកើតឡើង ឬបានកើតឡើងចាប់តាំងពីពេលតែងតាំង ដែលបានបង្កើតឲ្យមានការសង្ស័យដែលមិនអាចកែតម្រូវបានចំពោះភាពមិនលំអៀង ឬ ឯករាជ្យភាព មជ្ឈត្តករត្រូវបដិសេធមិនទទួលយកការតែងតាំង ឬ ប្រសិនបើដំណើរការមជ្ឈត្តការបានចាប់ផ្តើមហើយ មជ្ឈត្តករត្រូវដកខ្លួនពីការងារ លើកលែងតែគូភាគីវិវាទយល់ព្រមទទួលយកមជ្ឈត្តករនោះដោយផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦។

## ប្រការ៥.- ទំនាស់ផលប្រយោជន៍ និងកាតព្វកិច្ចលាតត្រដាង

៥.១ ប្រសិនបើគូភាគីវិវាទមើលឃើញថា មានហេតុ ឬ ស្ថានភាពណាមួយដែលអាចបង្កើតឲ្យមានភាពមន្ទិលទាក់ទងនឹងភាពមិនលំអៀង និងឯករាជ្យភាពរបស់មជ្ឈត្តករ ដូចបានរៀបរាប់នៅក្នុង **បញ្ជីពណ៌ទឹកក្រូច** និង**បញ្ជីពណ៌ក្រហម** មជ្ឈត្តករនោះត្រូវលាតត្រដាងអំពីរាល់ហេតុ ឬ ស្ថានភាពទាំងឡាយនោះជាលាយលក្ខណ៍អក្សរដល់គូភាគីវិវាទ ឬដល់គណៈកម្មាធិការតែងតាំងរបស់ ម.ជ.ម. នៅពេលដែលមជ្ឈត្តករនោះត្រូវបានតែងតាំងដោយគណៈកម្មាធិការតែងតាំង ឬ ដល់លេខាធិការដ្ឋានរបស់ ម.ជ.ម. និងដល់សហមជ្ឈត្តករ ប្រសិនបើមានមុនពេលទទួលយកការតែងតាំង ឬ ប្រសិនបើបានទទួលយកការតែងតាំងហើយនោះ ត្រូវលាតត្រដាងនៅពេលដែលមជ្ឈត្តករនោះបានដឹងអំពីហេតុ ឬ ស្ថានភាពទាំងនោះ។

៥.២ ត្រូវធ្វើតាមប្រការ ៤.១ ខាងលើ បើមជ្ឈត្តករដែលបានលាតត្រដាងព័ត៌មាននោះគិតថាខ្លួនគាត់មានភាពលំអៀង និងមិនមានឯករាជ្យភាពចំពោះគូភាគីវិវាទ ដោយមិនគិតពីអង្គហេតុដែលបានលាតត្រដាងនិងសមត្ថភាពក្នុងការបំពេញភារកិច្ចជាមជ្ឈត្តករ។

៥.៣ រាល់ភាពមន្ទិលសង្ស័យថាតើមជ្ឈត្តករគួរលាតត្រដាងនូវអង្គហេតុ ឬ កាលៈទេសៈណាមួយឬអត់នោះ គឺត្រូវបានដោះស្រាយតាមរយៈការលាតត្រដាង។

៥.៤ នៅពេលកំពុងពិចារណាថាតើអង្គហេតុ ឬ ស្ថានភាពដែលកើតឡើងនោះគួរលាតត្រដាងដែរឬទេ មជ្ឈត្តករមិនត្រូវបន្តដំណើរការមជ្ឈត្តការទេទោះបីស្ថិតក្នុងដំណាក់កាលចាប់ផ្តើម ឬ ដំណាក់កាលបន្ទាប់មកទៀតក៏ដោយ។

## ប្រការ៦.- ទំនាស់ផលប្រយោជន៍ និងការបោះបង់សិទ្ធិដោយគូភាគីវិវាទ

៦.១ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានទទួលការលាតត្រដាងពីមជ្ឈត្តករ ឬ ក្រោយពីភាគីណាមួយបានដឹងអំពីហេតុ ឬ ស្ថានភាព ដែលអាចបង្កើតឲ្យមានទំនាស់ផលប្រយោជន៍ធ្ងន់ធ្ងរជាមួយមជ្ឈត្តករ ប្រសិនបើមិនមានភាគីណាមួយបដិសេធចំពោះមជ្ឈត្តករនោះតាមប្រការ ៦.២ និងប្រការ៦.៣ខាងក្រោមទេ ត្រូវចាត់ទុកថាភាគីនោះបានបោះបង់ចោលនូវសិទ្ធិទាក់ទងនឹងទំនាស់ផលប្រយោជន៍ជាមួយមជ្ឈត្តករ ផ្អែកលើហេតុ ឬ ស្ថានភាពទាំងនោះ ហើយភាគីនោះគ្មានសិទ្ធិលើកយកហេតុ ឬ ស្ថានភាពនោះមកជំទាស់នៅក្នុងដំណើរការនីតិវិធីក្រោយៗទៀតទេ។

៦.២ ប៉ុន្តែ ប្រសិនបើកើតមានហេតុ ឬ ស្ថានភាពដូចមានចែងក្នុងប្រការ៤.១ខាងលើ ឧទាហរណ៍ ប្រសិនបើមជ្ឈត្តករខ្លួនឯង មានការសង្ស័យថាខ្លួនគ្មានឯករាជ្យភាព និងមានភាពលំអៀង ឬ មានហេតុដែលដែលបានកំណត់នៅក្នុង **បញ្ជីក្រហមដែលមិនអាចអនុគ្រោះបាន** ការបោះបង់សិទ្ធិចោលដោយភាគីណាមួយ ឬ ការរៀបចំណាមួយដោយគូភាគីវិវាទ ដើម្បីយកបុគ្គលនោះធ្វើជាមជ្ឈត្តកររបស់ខ្លួន ត្រូវចាត់ទុកថាគ្មានសុពលភាព។

៦.៣ បុគ្គលណាម្នាក់មិនគួរធ្វើជាមជ្ឈត្តករទេ ប្រសិនបើបុគ្គលនោះមានទំនាស់ផលប្រយោជន៍ ដូចបានលើកជាឧទាហរណ៍ក្នុង **បញ្ជីក្រហមដែលមិនអាចអនុគ្រោះបាន** កើតមានឡើង។ ប៉ុន្តែបុគ្គលនោះអាចទទួលការតែងតាំងជាមជ្ឈត្តករ ឬ បន្តធ្វើជាមជ្ឈត្តករបាន ប្រសិនបើលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ភាគីទាំងអស់ មជ្ឈត្តករទាំងអស់ និងគណៈកម្មាធិការតែងតាំងរបស់ ម.ជ.ម. នៅពេលដែលមជ្ឈត្តករនោះត្រូវបានតែងតាំងដោយគណៈកម្មាធិការនេះ ឬ លេខាធិការដ្ឋានរបស់ ម.ជ.ម.នៅគ្រប់ករណីផ្សេងទៀតទាំងអស់ បានដឹងច្បាស់អំពីទំនាស់ផលប្រយោជន៍នេះ និង
- ភាគីទាំងអស់បានបង្ហាញថា ខ្លួនយល់ព្រមឲ្យបុគ្គលនោះធ្វើជាមជ្ឈត្តកររបស់ខ្លួន ទោះបីជាមានទំនាស់ផលប្រយោជន៍ក៏ដោយ។

៦.៤ មជ្ឈត្តករមានករណីកិច្ចធ្វើការស្រាវជ្រាវ ដើម្បីរកឲ្យឃើញថាតើមានទំនាស់ផលប្រយោជន៍ជាសក្តានុពល ក៏ដូចជាហេតុ ឬ ស្ថានភាពដែលអាចធ្វើឲ្យខ្លួនលែងមានឯករាជ្យភាព និងមានភាពលំអៀងដែរឬទេ។ ប្រសិនបើមិនមានឆន្ទៈសមស្របណាមួយដើម្បីធ្វើការស្រាវជ្រាវទេនោះ មជ្ឈត្តករមិនអាចយកលេសថា ការខកខានមិនបានលាតត្រដាងអំពីទំនាស់ផលប្រយោជន៍នោះ គឺដោយសារខ្លួនមិនបានដឹងនោះឡើយ។

៦.៥ មជ្ឈត្តករអាចជួយគូភាគីវិវាទ ដើម្បីឈានដល់ការដោះស្រាយមួយស្របតាមវិធានមជ្ឈត្តការរបស់ ម.ជ.ម.។ ប៉ុន្តែមុនពេលជួយសម្របសម្រួលដល់គូភាគីវិវាទ មជ្ឈត្តករនោះគួរទទួលការយល់ព្រមយ៉ាងច្បាស់ពីគូភាគីថា ការធ្វើយ៉ាងដូច្នេះមិនធ្វើឲ្យមជ្ឈត្តករបាត់បង់សិទ្ធិក្នុងការបន្តធ្វើជាមជ្ឈត្តករនោះទេ។ ការយល់ព្រមនេះ ត្រូវចាត់ទុកថាជាការបោះបង់សិទ្ធិចំពោះទំនាស់ផលប្រយោជន៍ ដែលអាចកើតឡើងដោយសារការចូលរួមរបស់មជ្ឈត្តករនៅក្នុងដំណើរការមជ្ឈត្តការ ឬ ពីព័ត៌មានដែលមជ្ឈត្តករអាចទទួលបាននៅក្នុងដំណើរការនីតិវិធី។ ប្រសិនបើការសម្របសម្រួលរបស់មជ្ឈត្តករមិនអាចស្វែងរកដំណោះស្រាយចុងក្រោយបានទេ គូភាគីនៅតែជាប់កាតព្វកិច្ចនៃការបោះបង់សិទ្ធិនេះ។

**ប្រការ៧.- ទំនាស់ផលប្រយោជន៍ និងទំនាក់ទំនង**

៧.១ នៅពេលពិចារណាអំពីទំនាក់ទំនងហេតុ ឬ ស្ថានភាព ដើម្បីកំណត់ថាតើមានទំនាស់ផលប្រយោជន៍ដែរឬទេ ឬ ថាតើគួរលាតត្រដាងព័ត៌មានដែរឬទេ ជាគោលការណ៍មជ្ឈត្តករត្រូវចាត់ទុកដូចគ្នានឹងការិយាល័យមេធាវីរបស់ខ្លួនដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពរបស់ការិយាល័យមេធាវី

របស់មជ្ឈត្តករទាក់ទងនឹងភាគីម្ខាងទៀតនឹងមិនត្រូវចាត់ទុកជាមូលហេតុនៃទំនាស់ផលប្រយោជន៍ជាស្វ័យប្រវត្តិ ឬ បង្កើតជាមូលហេតុសម្រាប់លាតត្រដាងព័ត៌មានទេ។ ប៉ុន្តែទំនាក់ទំនងនៃសកម្មភាពដែលមានដូចជា ប្រភេទនៃការងារ ពេលវេលា និងទំហំការងាររបស់ការិយាល័យមេធាវីនោះនឹងត្រូវបានពិចារណាទៅតាមករណីនីមួយៗ។

៧.២ ដូចគ្នានេះដែរ ប្រសិនបើភាគីម្ខាងជានីតិបុគ្គលដែលជាសមាជិកនៃក្រុមណាមួយមានការពាក់ព័ន្ធនឹងការិយាល័យមេធាវីរបស់មជ្ឈត្តករនោះ អង្គហេតុ ឬ ស្ថានភាពនោះនឹងត្រូវពិចារណាទៅតាមករណីនីមួយៗ។ ហេតុដូច្នេះ ត្រឹមតែអង្គហេតុមិនអាចក្លាយជាទំនាស់ផលប្រយោជន៍ដោយស្វ័យប្រវត្តិ ឬ ក្លាយជាមូលហេតុសម្រាប់ការលាតត្រដាងព័ត៌មានទេ។

៧.៣ ប្រសិនបើភាគីម្ខាងជានីតិបុគ្គល អគ្គនាយក អភិបាល ឬ សមាជិកនៃក្រុមប្រឹក្សាភិបាលនៃនីតិបុគ្គលនោះ និងបុគ្គលផ្សេងទៀតដែលមានសិទ្ធិអំណាចប្រហាក់ប្រហែលក្នុងការគ្រប់គ្រងនីតិបុគ្គលនោះ ត្រូវចាត់ទុកថាដូចជានីតិបុគ្គលនោះដែរ។

## ប្រការ៨.- ទំនាស់ផលប្រយោជន៍ និងករណីយកិច្ចជូនដំណឹងរបស់គូភាគីវិវាទ

៨.១ ភាគីនីមួយៗត្រូវជូនដំណឹងដល់មជ្ឈត្តករ វេទិកាមជ្ឈត្តកម្ម ភាគីម្ខាងទៀត និងគណៈកម្មាធិការតែងតាំងរបស់ ម.ជ.ម. នៅពេលដែលមជ្ឈត្តករនោះត្រូវបានតែងតាំងដោយគណៈកម្មាធិការនេះ ឬ លេខាធិការដ្ឋានរបស់ ម.ជ.ម. អំពីទំនាក់ទំនងដោយផ្ទាល់ ឬ ប្រយោលរវាងភាគីជូនដំណឹង និង មជ្ឈត្តករ។ ភាគីនីមួយៗត្រូវធ្វើការជូនដំណឹងតាមគំនិតផ្តួចផ្តើមរបស់ខ្លួន មុនពេលចាប់ផ្តើមនីតិវិធីមជ្ឈត្តការ ឬ នៅពេលដែលខ្លួនបានដឹងពីទំនាក់ទំនងនោះ។

៨.២ ដើម្បីអនុវត្តតាមប្រការ៨.១ ខាងលើ ភាគីត្រូវផ្តល់ព័ត៌មានដែលខ្លួនបានទទួល ដូចបានកំណត់ក្នុងប្រការ៨.១ និងត្រូវធ្វើការស្រាវជ្រាវព័ត៌មានដែលអាចរកបានជាសាធារណៈ។

## ប្រការ៩.- ទំនាក់ទំនងជាមួយគូភាគីវិវាទ

៩.១ នៅមុនពេលទទួលការតែងតាំង មជ្ឈត្តករនោះគួរធ្វើការសាកសួរឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់ថាខ្លួនឯងអាចដោះស្រាយវិវាទ និងមានពេលវេលាគ្រប់គ្រាន់ ដើម្បីដំណើរការមជ្ឈត្តការដូចមានចែងក្នុងប្រការ២ខាងលើ។ មជ្ឈត្តករមិនត្រឹមតែត្រូវមានឯករាជ្យភាព និងភាពមិនលំអៀងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវមានសមត្ថភាពផងដែរ។ មជ្ឈត្តករអាចឆ្លើយតបទៅនឹងសំណួរទាំងឡាយពីអ្នកដែលមានបំណងចង់តែងតាំងខ្លួន ប្រសិនបើសំណួរទាំងនោះធ្វើឡើងក្នុងគោលបំណងកំណត់អំពីលក្ខណៈសម្បត្តិ ភាពទំនេរ ឯករាជ្យភាព និងភាពមិនលំអៀងសម្រាប់ការតែងតាំងនោះ និងប្រសិនបើសំណួរទាំងនោះមិនទាក់ទងនឹងអង្គហេតុសំខាន់ៗនៃវិវាទ។

ក្នុងករណីភាគីណាមួយ ឬមជ្ឈត្តករដែលបានតែងតាំងរួចដោយភាគីណាមួយ មានបំណងចង់តែងតាំងមជ្ឈត្តករណាម្នាក់ ឬប្រធានវេទិកាមជ្ឈត្តកម្ម មជ្ឈត្តករ ឬ ប្រធានវេទិកាមជ្ឈត្តកម្ម ដែលបម្រុង

ទទួលយកការតែងតាំងនោះត្រូវជូនដំណឹងដល់ភាគីម្ខាងទៀត ឬភាគីទាំងអស់ ឬមជ្ឈត្តករផ្សេងទៀត ដើម្បីទទួលស្គាល់ការតែងតាំងនោះ។

៩.២ ក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ មជ្ឈត្តករគួរជៀសវាងការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងសំណុំរឿងវិវាទ ជាឯកតោភាគីជាមួយគូភាគីវិវាទ ឬតំណាងគូភាគីវិវាទ។

៩.៣ ក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ លើកលែងតែនៅក្នុងសវនាការ ឬ ក្នុងកិច្ចប្រជុំ មជ្ឈត្តករត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយគូភាគីវិវាទ ឬ តំណាងគូភាគីវិវាទបានត្រឹមតែក្នុងទម្រង់ជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

៩.៤ ប្រសិនបើមជ្ឈត្តករបានដឹងថា សហមជ្ឈត្តករណាម្នាក់មានការទាក់ទងជាមួយភាគីណាមួយខុសប្រក្រតី ឬ បានធ្វើសកម្មភាព ឬ កំពុងធ្វើសកម្មភាពបំពានក្រមសីលធម៌នេះ មជ្ឈត្តករនោះត្រូវជូនដំណឹងដល់មជ្ឈត្តករផ្សេងទៀត ហើយមជ្ឈត្តករទាំងអស់នៃវេទិកាមជ្ឈត្តកម្មនឹងកំណត់ថាតើគួរចាត់វិធានការបែបណា។ ជាធម្មតា វិធានការបឋមដែលសមរម្យសម្រាប់មជ្ឈត្តករដែលបំពានក្រមសីលធម៌នេះ គឺស្នើឲ្យមជ្ឈត្តករនោះជៀសវាងពីការទាក់ទងជាមួយភាគីណាមួយខុសប្រក្រតី ឬ ពីការប្រព្រឹត្តមិនសមរម្យណាមួយតទៅទៀត។ ប្រសិនបើមជ្ឈត្តករនោះខកខាន ឬ បដិសេធក្នុងការជៀសវាងពីការទាក់ទងខុសប្រក្រតី ឬ ពីការប្រព្រឹត្តមិនសមរម្យណាមួយនោះ មជ្ឈត្តករផ្សេងទៀតអាចជូនដំណឹងដល់ភាគីម្ខាងទៀតដើម្បីឲ្យភាគីនោះពិចារណាអំពីការចាត់វិធានការណាមួយ។ មជ្ឈត្តករអាចជូនដំណឹងដល់ភាគីណាមួយជាឯកតោភាគីបាន អំពីសកម្មភាពរបស់មជ្ឈត្តករផ្សេងទៀតដើម្បីឲ្យភាគីនោះពិចារណាអំពីបញ្ហាប្រឈមទាក់ទងនឹងមជ្ឈត្តករដែលបំពានលើក្រមសីលធម៌ តែក្នុងករណីដែលមានការបំពានធ្ងន់ធ្ងរ និងក្រោយពេលដែលខ្លួនបានជូនដំណឹងអំពីហេតុការណ៍នោះទៅកាន់មជ្ឈត្តករផ្សេងទៀតជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។

៩.៥ មជ្ឈត្តករដែលតែងតាំងឡើងឲ្យដោះស្រាយវិវាទតែម្នាក់ ឬ ប្រធានវេទិកាមជ្ឈត្តកម្ម គួរជៀសវាងប្រាស្រ័យទាក់ទងជាមួយភាគីណាមួយនៃដំណើរការមជ្ឈត្តការជាលក្ខណៈសង្គម ឬ លក្ខណៈវិជ្ជាជីវៈដោយគ្មានវត្តមានរបស់ភាគីម្ខាងទៀត។

៩.៦ មជ្ឈត្តករមិនគួរទទួលយកអំណោយ ឬ ទទួលបដិសណ្ឋារកិច្ច ទោះដោយផ្ទាល់ ឬ ដោយប្រយោលពីភាគីណាមួយនៃដំណើរការមជ្ឈត្តការឡើយ។

**ប្រការ១០.- កម្រៃ**

១០.១ ក្នុងការទទួលយកការតែងតាំង មជ្ឈត្តករត្រូវយល់ព្រមទៅលើកម្រៃ និងការចំណាយដែលកំណត់ដោយ ម.ជ.ម.។ មជ្ឈត្តករមិនត្រូវរៀបចំកម្រៃ និងការចំណាយជាឯកតោភាគីនោះទេ។

១០.២ ការដោះស្រាយបញ្ហាទាក់ទងនឹងកម្រៃ និងចំណាយរបស់មជ្ឈត្តករត្រូវស្ថិតនៅក្រោមវិធានមជ្ឈត្តការ និងវិធានជាធរមានដទៃទៀតរបស់ ម.ជ.ម.។

**ប្រការ១១.- ការសម្ងាត់**

រាល់ការពិភាក្សានៅក្នុងសវនាការមជ្ឈត្តការ ត្រូវរក្សាជាការសម្ងាត់ជារៀងរហូត លើកលែងតែគូភាគីវិវាទអនុញ្ញាតឲ្យមជ្ឈត្តកររួចផុតពីកាតព្វកិច្ចនេះ។ ខ្លឹមសារនៃសេចក្តីសម្រេចត្រូវរក្សាជាការសម្ងាត់ លើកលែងតែសេចក្តីសម្រេចនោះត្រូវបានបោះពុម្ពផ្សាយស្របតាមវិធានមជ្ឈត្តការរបស់ ម.ជ.ម.។

មជ្ឈត្តករមិនគួរចូលរួម ឬ ផ្តល់ព័ត៌មានក្នុងដំណើរការនីតិវិធីមជ្ឈត្តការណាមួយដែលអាចមានឥទ្ធិពលដល់ការចេញសេចក្តីសម្រេចនោះទេ លើកលែងតែមជ្ឈត្តករនោះគិតថាខ្លួនមានករណីយកិច្ចត្រូវលាតត្រដាងរាល់កំហុសធ្ងន់ធ្ងររបស់សហមជ្ឈត្តករដទៃទៀត។

**ប្រការ១២.- ការអនុវត្តដំណើរការនីតិវិធីមជ្ឈត្តការ**

១២.១ មជ្ឈត្តករទាំងអស់ត្រូវលះបង់ពេលវេលា និងផ្តល់ការយកចិត្តទុកដាក់គ្រប់កាលៈទេសៈនៃវិវាទ តាមការតម្រូវសមស្របរបស់គូភាគីវិវាទ និងត្រូវព្យាយាមអនុវត្តដំណើរការនីតិវិធីមជ្ឈត្តការទៅតាមលក្ខណៈមួយដែលមិនបង្កឲ្យមានការចំណាយមិនសមហេតុផល។

១២.២ នៅក្នុងអំឡុងពេលមួយសមស្រប បន្ទាប់ពីចេញសេចក្តីសម្រេច មជ្ឈត្តករត្រូវជៀសវាងសកម្មភាពណាមួយដែលបានកំណត់នៅក្នុងប្រការ ៩.៣ ប្រការ ៩.៦ និងប្រការ ៩.៧ ខាងលើ ដែលអាចនាំឲ្យភាគីម្ខាង ឬ បុគ្គលផ្សេងទៀតជឿជាក់ថា សេចក្តីសម្រេចដែលបានធ្វើដោយផ្អែកលើភាពមិនប្រក្រតី ។

១២.៣ តាមរយៈគណៈកម្មាធិការតែងតាំងរបស់ខ្លួន ម.ជ.ម. ត្រូវជំរុញ និងត្រួតពិនិត្យការប្រតិបត្តិតាមក្រមសីលធម៌របស់មជ្ឈត្តករដែលជាសមាជិកនៃ ម.ជ.ម. ឬ ការអនុវត្តដំណើរការនីតិវិធីមជ្ឈត្តការដែលគ្រប់គ្រងដោយ ម.ជ.ម.។ មជ្ឈត្តករត្រូវមានឆន្ទៈក្នុងការពិភាក្សាជាមួយ ម.ជ.ម. ឬ គណៈកម្មាធិការរបស់ ម.ជ.ម. អំពីមតិកែលម្អ ឬ ការរិះគន់ដែលទទួលបានពីគូភាគីវិវាទ ឬ បុគ្គលផ្សេងទៀតក្នុងអំឡុងពេល ឬ ក្រោយពេលដំណើរការនីតិវិធីមជ្ឈត្តការទាក់ទងនឹងការងាររបស់ខ្លួន ជាពិសេសទាក់ទងនឹងការបំពានណាមួយលើក្រមសីលធម៌ ឬ បទប្បញ្ញត្តិជាធរមានរបស់ ម.ជ.ម. ។

**ប្រការ១៣.- បទប្បញ្ញត្តិផ្សេងៗ**

១៣.១ ក្រមសីលធម៌នេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នាថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥។

១៣.២ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងក្រមសីលធម៌នេះត្រូវទុកជានិរាករណ៍។ ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥ តទៅ។

រាជធានីភ្នំពេញ

**ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកាផ្នែកពាណិជ្ជកម្ម**

**មជ្ឈត្តករ រស់ មុនិន្ទះ**

# ឧបសម្ព័ន្ធ

**១.　បញ្ជីក្រហមដែលមិនអាចអនុគ្រោះបាន**

បុគ្គលណាម្នាក់មិនត្រូវធ្វើជាមជ្ឈត្តករទេ ប្រសិនបើបុគ្គលនោះស្ថិតក្នុងស្ថានភាពដូចខាងក្រោម៖

១.១ មានទំនាក់ទំនងជិតស្និតជាមួយភាគីណាមួយ ឬ មជ្ឈត្តករនោះជាអ្នកតំណាងស្របច្បាប់របស់ស្ថាប័នណាមួយដែលជាភាគីវិវាទនៅក្នុងដំណើរការមជ្ឈត្តការ។

១.២ ជាអគ្គនាយក អភិបាល សមាជិកនៃក្រុមប្រឹក្សាភិបាល ឬ អ្នកមានឥទ្ធិពលប្រហាក់ប្រហែលក្នុងស្ថាប័នដែលជាភាគីវិវាទនៅក្នុងដំណើរការមជ្ឈត្តការ។

១.៣ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីភាគីណាមួយ ឬ ទទួលបានផលប្រយោជន៍ពីលទ្ធផលនៃវិវាទនោះ។

១.៤ ផ្ដល់ការពិគ្រោះយោបល់ទៀងទាត់ដល់ភាគីវិវាទដែលបានតែងតាំងខ្លួន ឬ ក្រុមហ៊ុនរបស់ភាគីវិវាទនោះ ហើយមជ្ឈត្តករ ឬ ការិយាល័យមេធាវីរបស់មជ្ឈត្តករនោះ ទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុយ៉ាងច្រើនពីការផ្ដល់ការពិគ្រោះយោបល់នោះ។

**២.　បញ្ជីក្រហមដែលអាចអនុគ្រោះបាន**

បុគ្គលណាម្នាក់មិនគួរធ្វើជាមជ្ឈត្តករទេ ប្រសិនបើបុគ្គលនោះស្ថិតក្នុងស្ថានភាពដូចខាងក្រោម៖

២.១ <u>ទំនាក់ទំនងរបស់មជ្ឈត្តករនៅក្នុងវិវាទ</u>

២.១.១ ធ្លាប់បានផ្ដល់យោបល់ ឬ ផ្ដល់គំនិតស៊ីជម្រៅទាក់ទងនឹងវិវាទ ដល់ភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីណាមួយ។

២.១.២ បានចូលរួមក្នុងវិវាទនោះម្ដងរួចមកហើយ។

២.២ <u>ផលប្រយោជន៍ដោយផ្ទាល់ ឬ ដោយប្រយោលរបស់មជ្ឈត្តករក្នុងវិវាទ</u>

២.២.១ មជ្ឈត្តករកាន់កាប់ភាគហ៊ុនទោះបីដោយផ្ទាល់ ឬ ដោយប្រយោលក្ដី របស់ភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីណាមួយជាលក្ខណៈឯកជន។

២.២.២ សមាជិកជិតស្និទ្ធនៃគ្រួសាររបស់មជ្ឈត្តករ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុយ៉ាងច្រើនពីលទ្ធផលនៃវិវាទ។

២.២.៣ មជ្ឈត្តករ ឬ សមាជិកជិតស្និទ្ធនៃគ្រួសាររបស់មជ្ឈត្តករនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយតតីយជន ដែលតតីយជននោះ មានឥទ្ធិពលធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃដំណើរការមជ្ឈត្តការ។

២.៣ <u>ទំនាក់ទំនងមជ្ឈត្តករជាមួយគូភាគីវិវាទ ឬ ទីប្រឹក្សា</u>

២.៣.១ មជ្ឈត្តករធ្វើជាអ្នកតំណាង ឬ ផ្ដល់យោបល់ដល់ភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីណាមួយ។

២.៣.២ មជ្ឈត្តករធ្វើជាទីប្រឹក្សារបស់មេធាវី ឬ ការិយាល័យមេធាវី ដែលជាទីប្រឹក្សារបស់ភាគីណាមួយ។

២.៣.៣ មជ្ឈត្តករ គឺជាមេធាវីនៅក្នុងការិយាល័យមេធាវីដែលជាទីប្រឹក្សារបស់ភាគីមួយ។

២.៣.៤ មជ្ឈត្តករជាអគ្គនាយក អភិបាល សមាជិកនៃក្រុមប្រឹក្សាភិបាល ឬ អ្នកមានឥទ្ធិពលប្រហាក់ប្រហែលនៅក្នុងក្រុមហ៊ុនមេ ឬដែលក្រុមហ៊ុនបុត្តសម្ព័ន ចូលរួមដោយផ្ទាល់ជាភាគីវិវាទក្នុងដំណើរការមជ្ឈត្តការ។

២.៣.៥ ការិយាល័យមេធាវីរបស់មជ្ឈត្តករធ្លាប់បានចូលរួមក្នុងវិវាទ ប៉ុន្តែមជ្ឈត្តករនោះមិនធ្លាប់បានចូលរួមទេ។

២.៣.៦ ការិយាល័យមេធាវីរបស់មជ្ឈត្តករ កំពុងមានទំនាក់ទំនងផ្នែកពាណិជ្ជកម្មយ៉ាងខ្លាំងជាមួយភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីនោះ។

២.៣.៧ មជ្ឈត្តករផ្តល់យោបល់យ៉ាងទៀងទាត់ដល់ភាគីដែលតែងតាំងមជ្ឈត្តករនោះ ឬ ក្រុមហ៊ុនរបស់ភាគីនោះ ប៉ុន្តែទាំងមជ្ឈត្តករ ទាំងការិយាល័យរបស់មជ្ឈត្តករនោះមិនបានទទួលផលប្រយោជន៍ហិរញ្ញវត្ថុច្រើនពីការផ្តល់យោបល់នោះទេ។

២.៣.៨ មជ្ឈត្តករមានទំនាក់ទំនងគ្រួសារយ៉ាងជិតស្និទ្ធជាមួយភាគីម្ខាង ឬជាមួយអគ្គនាយក អភិបាល សមាជិកនៃក្រុមប្រឹក្សាភិបាល ឬ អ្នកមានឥទ្ធិពលប្រហាក់ប្រហែលនៅក្នុងក្រុមហ៊ុន ឬ ជាមួយទីប្រឹក្សាដែលជាអ្នកតំណាងភាគីនោះ។

២.៣.៩ សមាជិកជិតស្និទ្ធរបស់គ្រួសារមជ្ឈត្តករណាម្នាក់ មានផលប្រយោជន៍ហិរញ្ញវត្ថុយ៉ាងច្រើន ពីភាគីណាមួយ ឬ ពីក្រុមហ៊ុនរបស់ភាគីនោះ។

## ៣. បញ្ជីពណ៌ទឹកក្រូច

បុគ្គលណាម្នាក់អាចទទួលការតែងតាំងជាមជ្ឈត្តករ ប្រសិនបើបុគ្គលនោះស្ថិតក្នុងស្ថានភាពដូចខាងក្រោម៖

៣.១ <u>ធ្លាប់បានផ្តល់សេវាដល់ភាគីណាមួយ ឬ ការចូលរួមផ្សេងទៀតក្នុងវិវាទ</u>

៣.១.១ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ មជ្ឈត្តករបានធ្វើជាទីប្រឹក្សាឲ្យភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីណាមួយ ឬ បានផ្តល់យោបល់ ឬ បានផ្តល់ប្រឹក្សាឲ្យភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីដែលបានធ្វើការតែងតាំងខ្លួន លើបញ្ហាដែលមិនទាក់ទងនឹងវិវាទនេះទេ ប៉ុន្តែមជ្ឈត្តករ និងភាគី ឬ ក្រុមហ៊ុនរបស់ភាគីនោះមិនមានទំនាក់ទំនងនឹងគ្នាទៀតទេ។

៣.១.២ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ មជ្ឈត្តករបានធ្វើជាទីប្រឹក្សាឲ្យភាគីមួយផ្សេងទៀត ដើម្បីតទល់នឹងភាគីណាមួយនៃវិវាទនេះ ឬ ក្រុមហ៊ុនរបស់ភាគីនោះលើបញ្ហាដែលមិនទាក់ទងនឹងវិវាទនេះទេ។

៣.១.៣ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ មជ្ឈត្តករត្រូវបានតែងតាំងជាមជ្ឈត្តករដោយភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីនោះ ពីរដង ឬ ច្រើនជាងនេះ។

៣.១.៤ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ ការិយាល័យមេធាវីរបស់មជ្ឈត្តករបានធ្វើជាអ្នកតំណាងឲ្យភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីនោះលើបញ្ហាដែលមិនទាក់ទងនឹងវិវាទនេះទេ ហើយមជ្ឈត្តករក៏មិនបានចូលរួមក្នុងវិវាទនោះដែរ។

៣.១.៥ មជ្ឈត្តករកំពុង ឬ បានធ្វើជាមជ្ឈត្តករនៅក្នុងដំណើរការនីតិវិធីមជ្ឈត្តការមួយ

ផ្សេងទៀតលើបញ្ហាពាក់ព័ន្ធនឹងវិវាទដែលចូលរួមដោយភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីនោះក្នុងអំឡុងពេលមួយឆ្នាំចុងក្រោយ។

៣.២ <u>សេវាដែលកំពុងផ្តល់ឲ្យភាគីណាមួយ</u>

៣.២.១ ការិយាល័យមេធាវីរបស់មជ្ឈត្តករកំពុងផ្តល់សេវាឱ្យភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័នរបស់ភាគីណាមួយ ប៉ុន្តែទំនាក់ទំនងនោះវាមិនបង្កើតឲ្យមានទំនាក់ទំនងផ្នែកពាណិជ្ជកម្មខ្លាំងក្លា ហើយមជ្ឈត្តករនោះមិនបានចូលរួមក្នុងទំនាក់ទំនងនោះទេ។

៣.២.២ ការិយាល័យមេធាវីដែលចែករំលែកប្រាក់ចំណូល ឬប្រាក់កម្រៃសេវាឲ្យការិយាល័យ មេធាវីរបស់មជ្ឈត្តករកំពុងផ្តល់សេវាឲ្យភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័នរបស់ភាគីនោះមុនការបង្កើតវេទិកាមជ្ឈត្តកម្ម។

៣.២.៣ មជ្ឈត្តករ ឬ ការិយាល័យមេធាវីរបស់មជ្ឈត្តករនោះ ធ្វើជាអ្នកតំណាងដោយអាណត្តិឲ្យភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័នរបស់ភាគីនោះជាទៀងទាត់ក្នុងរាល់ដំណើរការមជ្ឈត្តការ ប៉ុន្តែរាល់សកម្មភាពតំណាងនោះមិនពាក់ព័ន្ធនឹងវិវាទបច្ចុប្បន្នទេ។

៣.៣ <u>ទំនាក់ទំនងរវាងមជ្ឈត្តករ និងមជ្ឈត្តករ ឬ ទីប្រឹក្សាផ្សេងទៀត</u>

៣.៣.១ មជ្ឈត្តករមួយរូប និងមជ្ឈត្តករមួយរូបផ្សេងទៀត ជាមេធាវីដែលធ្វើការនៅក្នុងការិយាល័យមេធាវីតែមួយ។

៣.៣.២ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ មជ្ឈត្តករធ្លាប់ជាដៃគូសហការ ឬចូលរួមក្នុងការងារជាមួយមជ្ឈត្តករ ឬ អ្នកផ្តល់ប្រឹក្សាមួយរូបផ្សេងទៀតនៅក្នុងដំណើរការមជ្ឈត្តការតែមួយ។

៣.៣.៣ មេធាវីដែលធ្វើការនៅក្នុងការិយាល័យមេធាវីរបស់មជ្ឈត្តករ គឺជាមជ្ឈត្តករនៅក្នុងវិវាទផ្សេងទៀត ដែលមានភាគីម្ខាង ឬគូភាគីដូចគ្នា ឬជាអ្នកធ្វើការឲ្យភាគីណា មួយ។

៣.៣.៤ សមាជិកជិតស្និទ្ធនៃគ្រួសាររបស់មជ្ឈត្តករ ជាដៃគូសហការ ឬ ជានិយោជិតរបស់ការិយាល័យមេធាវីដែលតំណាងឲ្យភាគីណាមួយ ប៉ុន្តែបុគ្គលនោះមិនបានចូលរួមពាក់ព័ន្ធនឹងវិវាទនោះទេ។

៣.៣.៥ ទំនាក់ទំនងផ្ទាល់ខ្លួនជិតស្និទ្ធ រវាងមជ្ឈត្តករ និងទីប្រឹក្សារបស់ភាគីណាមួយដែលមជ្ឈត្តករ និងទីប្រឹក្សានោះចំណាយពេលវេលាជាមួយគ្នាច្រើន ប៉ុន្តែទំនាក់ទនងនោះ មិនពាក់ព័ន្ធនឹងការងារ គឺវាគ្រាន់តែជាសកម្មភាពនៃសមាគមវិជ្ជាជីវៈ ឬ អង្គការសង្គមណាមួយតែប៉ុណ្ណោះ។

៣.៣.៦ ក្នុងអំឡុងពេលមួយឆ្នាំចុងក្រោយ មជ្ឈត្តករបានទទួលការតែងតាំងបីដងជាមជ្ឈត្តករដោយទីប្រឹក្សា ឬ ការិយាល័យមេធាវីតែមួយ។

៣.៤ ទំនាក់ទំនងរវាងមជ្ឈត្តករ និងភាគីណាមួយ និងភាគីផ្សេងទៀតដែលពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ

៣.៤.១ ការិយាល័យមេធាវីរបស់មជ្ឈត្តករ កំពុងធ្វើសកម្មភាពបណ្ដឹងប្រឆាំងនឹងភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ភាគីនោះ។

៣.៤.២ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ មជ្ឈត្តករធ្លាប់ពាក់ព័ន្ធជាមួយភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីនោះបែបវិជ្ជាជីវៈ ដូចជាអតីតនិយោជិត ឬ ដៃគូសហការ។

៣.៤.៣ ទំនាក់ទំនងផ្ទាល់ខ្លួនជិតស្និទ្ធ រវាងមជ្ឈត្តករ និងអគ្គនាយក អភិបាល ឬ សមាជិកនៃក្រុមប្រឹក្សាភិបាលនៃនីតិបុគ្គលនោះ ឬបុគ្គលដែលមានឥទ្ធិពលប្រហាក់ប្រហែលរបស់ភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ភាគីនោះ ឬ សាក្សី ឬ អ្នកជំនាញរបស់ភាគីនោះដែលមជ្ឈត្តករ និងអគ្គនាយក អភិបាល សាក្សី ឬ អ្នកជំនាញនោះចំណាយពេលវេលាជាមួយគ្នាច្រើន ប៉ុន្តែទំនាក់ទំនងនោះ មិនពាក់ព័ន្ធនឹងការងារទេ វាគ្រាន់តែជាសកម្មភាពនៃសមាគមវិជ្ជាជីវៈ ឬ អង្គការសង្គមណាមួយតែប៉ុណ្ណោះ។

៣.៥ កាលៈទេសៈផ្សេងទៀត

៣.៥.១ មជ្ឈត្តករកាន់កាប់ភាគហ៊ុនតិចតួច នៃបុគ្គលដែលជាភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីនោះ ដែលបានចុះបញ្ជីជាសាធារណៈដោយផ្ទាល់ ឬដោយប្រយោល។

៣.៥.២ មជ្ឈត្តករ បានបង្ហាញគោលជំហរជាក់លាក់របស់ខ្លួនជាសាធារណៈតាមរយៈការបោះផ្សាយ ឬ ការថ្លែងការណ៍ ឬមធ្យោបាយណាមួយផ្សេងទៀតទាក់ទងនឹងវិវាទដែលកំពុងត្រូវបានធ្វើដំណើរការមជ្ឈត្តការ។

៣.៥.៣ មជ្ឈត្តករមានតួនាទីមួយនៅក្នុងស្ថាប័នមជ្ឈត្តការ ដែលមានអំណាចតែងតាំងមជ្ឈត្តករសម្រាប់ដោះស្រាយវិវាទ។

៣.៥.៤ មជ្ឈត្តករជាអគ្គនាយក អភិបាល សមាជិកនៃក្រុមប្រឹក្សាភិបាល ឬ អ្នកមានឥទ្ធិពលប្រហាក់ប្រហែលក្នុងក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ភាគីណាមួយ ដែលក្រុមហ៊ុនបុត្តសម្ព័ន្ធនោះមិនជាប់ពាក់ព័ន្ធនឹងវិវាទដោយផ្ទាល់ក្នុងដំណើរការមជ្ឈត្តការទេ។

## ៤. បញ្ជីបៃតង

បុគ្គលណាម្នាក់មិនគួរបដិសេធមិនធ្វើជាមជ្ឈត្តករទេ ប្រសិនបើបុគ្គលនោះស្ថិតក្នុងស្ថានភាពដូចខាងក្រោម៖

៤.១ ធ្លាប់បានផ្ដល់យោបល់ផ្នែកច្បាប់

៤.១.១ មជ្ឈត្តករធ្លាប់បានចុះផ្សាយយោបល់ទូទៅ ដូចជាអត្ថបទច្បាប់ ឬ បទបង្ហាញជាសាធារណៈទាក់ទងនឹងបញ្ហាដែលកើតមាននៅក្នុងដំណើរការមជ្ឈត្តការ ប៉ុន្តែយោបល់នេះមិនផ្ដោតលើវិវាទដែលបានកំពុងដោះស្រាយនៅក្នុងដំណើរការមជ្ឈត្តការទេ។

៤.២ ធ្លាប់ធ្វើសកម្មភាពបណ្ដឹងប្រឆាំងនឹងភាគីណាមួយ

៤.២.១ ការិយាល័យមេធាវីរបស់មជ្ឈត្តករបានធ្វើសកម្មភាពបណ្ដឹងប្រឆាំងនឹងភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័នរបស់ភាគីនោះ ប៉ុន្តែមជ្ឈត្តករនោះមិនបានចូលរួមពាក់ព័ន្ធទេ។

៤.៣ សេវាដែលកំពុងផ្តល់ដល់ភាគីណាមួយ

៤.៣.១ ការិយាល័យសាខា ឬដៃគូសហការនៃការិយាល័យមេធាវីរបស់មជ្ឈត្តករ ដែលមិនបែងចែកប្រាក់កម្រៃសេវា ឬ ប្រាក់ចំណូលជាមួយគ្នា បានផ្តល់សេវាដល់ភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័នរបស់ភាគីនោះ ប៉ុន្តែបញ្ហានោះមិនពាក់ព័ន្ធនឹងវិវាទក្នុងដំណើរការមជ្ឈត្តការទេ។

៤.៤ ទំនាក់ទំនងជាមួយមជ្ឈត្តករផ្សេងទៀត ឬ ទីប្រឹក្សារបស់ភាគីណាមួយ

៤.៤.១ មជ្ឈត្តករមានទំនាក់ទំនងជាមួយមជ្ឈត្តករផ្សេងទៀត ឬ ទីប្រឹក្សារបស់ភាគីណាមួយ តាមរយៈសមាជិកភាពរបស់សមាគមន៍វិជ្ជាជីវៈ ឬ អង្គការសង្គមតែមួយ។

៤.៤.២ មជ្ឈត្តករ និងទីប្រឹក្សារបស់ភាគីណាមួយ ឬ មជ្ឈត្តករផ្សេងទៀត ធ្លាប់បានធ្វើជាសហមជ្ឈត្តករ ឬ សហទីប្រឹក្សា។

៤.៥ ទំនាក់ទំនងរវាងមជ្ឈត្តករ ជាមួយភាគីណាមួយ

៤.៥.១ មជ្ឈត្តករធ្លាប់មានទំនាក់ទំនងជាមួយភាគីដែលតែងតាំងខ្លួន ឬ ក្រុមហ៊ុនរបស់ភាគីនោះ ឬ ទីប្រឹក្សារបស់ភាគីនោះ មុនពេលតែងតាំងខ្លួន ប្រសិនបើទំនាក់ទំនងនេះគឺគ្រាន់តែដើម្បីចង់ដឹងពីភាពទំនេរ និងគុណវុឌ្ឍិរបស់មជ្ឈត្តករ ដើម្បីឲ្យធ្វើជាប្រធានវេទិកាមជ្ឈត្តកម្ម ប៉ុន្តែទំនាក់ទំនងនោះមិនពិភាក្សាអំពីនីតិវិធី ឬ អង្គសេចក្តីនៃវិវាទទេ។

៤.៥.២ មជ្ឈត្តករកាន់កាប់ភាគហ៊ុនតិចតួចក្នុងក្រុមហ៊ុនរបស់ភាគីណាមួយ ឬ ក្រុមហ៊ុនបុត្តសម្ព័នរបស់ភាគីនោះ ដែលបានចុះបញ្ជីជាសាធារណៈ។

៤.៥.៣ មជ្ឈត្តករ និងអគ្គនាយក អភិបាល សមាជិកនៃក្រុមប្រឹក្សាភិបាល ឬ អ្នកមានឥទ្ធិពលប្រហាក់ប្រហែលរបស់ភាគីណាមួយ ឬ ក្រុមហ៊ុនរបស់ភាគីនោះ បានធ្វើការរួមគ្នាក្នុងឋានៈជាសហជំនាញការ ឬ ក្នុងវិជ្ជាជីវៈផ្សេងទៀតជាមួយគ្នា ឬជាសហមជ្ឈត្តករនៅក្នុងសំណុំរឿងវិវាទតែមួយ។

**កំណត់ចំណាំ**

១. ពាក្យថា "ទំនាក់ទំនងជិតស្និទ្ធនៅក្នុងគ្រួសារ" សំដៅលើសហព័ទ្ធ បងប្អូនបង្កើត កូន ឪពុក ម្តាយ ឬ បុគ្គលដែលរស់នៅជាមួយគ្នាជាអនិតិសង្វាស។

២. ពាក្យថា "ក្រុមហ៊ុន" សំដៅលើក្រុមហ៊ុនទាំងអស់ ដែលនៅក្នុងសម្ព័ន្ធក្រុមហ៊ុន រួមទាំងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្តសម្ព័ន។